FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ

ឆ្នាំទី ៦ លេខ ៦២ ខែកក្កដា ឆ្នាំ ២០០៧

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute



# ពូជពោត "លឿងមង្គល"

ពូជ "លឿងមង្គល" គឺជាពូជពោតដែលបានធ្វើការរំដោះ និងផ្សព្វផ្សាយដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នាចុងឆ្នាំ ២០០៦។ បន្ទាប់ពីបានធ្វើការពិសោធន៍អស់រយៈពេលប្រាំមួយរដូវ (បីឆ្នាំ) កន្លងមក។ បច្ចុប្បន្នពូជពោត "លឿងមង្គល" បាននឹងកំពុងផ្សព្វផ្សាយក្នុងចំណោមប្រជាកសិករ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## លក្ខណៈពិសេសរបស់ពូជពោត "លឿងមង្គល"

### លក្ខណៈរូបសាស្ត្រ



ពូជពោត "លឿងមង្គល" មានលក្ខណៈដើមដងរឹងមាំ ស្លឹកមានពណ៌បៃតងចាស់ ហើយដុះលូតលាស់យ៉ាងលឿនបន្ទាប់ពីដាំបាន ១៥-២០ ថ្ងៃ។ ប្រព័ន្ធឫសមានការដុះលូតលាស់យ៉ាងខ្លាំង មានតួនាទីទប់ដើមមិនឲ្យដួលរលំដោយសារខ្យល់ និងនៅពេលដើមចាប់ផ្តើមស្ងួតឬងាប់។ ដើមមានកម្ពស់ជាមធ្យមពី ២ ទៅ ២.៥ ម៉ែត្រ។ កម្ពស់ផ្លែពីដីគឺពី ៨៥ សង់ទីម៉ែត្រ ទៅ ១ ម៉ែត្រ។ ផ្លែមានរាងទ្រវែងប្រវែងពី ១៥ សង់ទីម៉ែត្រ រហូតដល់ ៣០ សង់ទីម៉ែត្រ។ គ្រាប់មានពណ៌លឿងចាស់រាងដូចធ្មេញកោងរលោងផ្នែកខាងខ្នង ចំនួនជួររបស់គ្រាប់ក្នុងមួយផ្លែពី ១២-១៦ ជួរ និងទម្ងន់ ១០០០ គ្រាប់ស្មើនឹង ៣០០ ក្រាម។ ពូជពោត "លឿងមង្គល" អាចផ្តល់ទិន្នផលជាមធ្យមគឺ ៤.០ តោន ក្នុងមួយហិកតា ហើយបើក្នុងលក្ខខណ្ឌល្អអាចផ្តល់ផលរហូតដល់ ១០ តោន ក្នុងមួយហិកតា។ ការដាំដុះពូជពោត "លឿងមង្គល" លើផ្ទៃដីមួយហិកតា ត្រូវការពូជពី ៣០ ទៅ ៣៥ គីឡូក្រាម (ដាំ ២-៣ គ្រាប់ ក្នុងមួយគុម្ព)។

## វិធីសាស្ត្រដាំដុះ

គេអាចធ្វើការដាំដុះដំណាំពោតបានពេញមួយឆ្នាំ ដោយការបុកដាំ ការដាំជាជួរ ឬដាំតាមចង្អូរដូចតារាងខាងក្រោម។ មុនពេលដាំត្រូវយកគ្រាប់ពូជមកត្រាំទឹកឲ្យបានពី ៤-៦ ម៉ោង ដើម្បីឲ្យគ្រាប់រីកឆាប់ដុះ (តំបន់ដែលមានទឹកគ្រប់គ្រាន់)ដោយដាក់គ្រាប់ក្នុងមួយរណ្តៅពី ២-៣ គ្រាប់ និងជម្រៅពី ២-៤ ស.ម។ ត្រូវធ្វើការស្រោចស្រពដីឲ្យបានជោគក្រោយពេលដាំ (នៅរដូវប្រាំង)។ ចំពោះតំបន់ដាំដុះដែលរំពឹងទឹកភ្លៀង គឺយើងត្រូវដាក់ដាំគ្រាប់ផ្ទាល់តែម្តង ដោយមិនចាំបាច់ត្រាំទឹកទេ។ ការកាត់រំលោះដើម គឺអាចធ្វើនៅពេលកូនដំណាំមានអាយុបាន ១០ ទៅ ១៥ ថ្ងៃ ដោយទុកតែមួយដើមក្នុងមួយគុម្ព និងធ្វើការសម្អាតស្មៅឲ្យស្អាត ចៀសវាងការប្រជែងស្រូបយកជីជាតិពីដំណាំ ដែលធ្វើឲ្យដំណាំក្រិនមិនសូវលូតលាស់ និងផ្តល់ផលតិច។

| ចន្លោះជួរ (ស.ម) | ចន្លោះគុម្ព (ស.ម) | |
|---|---|---|
| | ដើម/គុម្ព | ដើម/គុម្ព |
| ៦៥ | ៣០ | ៦០ |
| ៧០-៨០ | ២៥ | ៥៥ |
| ៨៥-៩៥ | ២០ | ៤០ |

## ការដុះលូតលាស់

ការធ្វើដីបានផុសល្អ ដីមានជីជាតិ សំណើមគ្រប់គ្រាន់ និងធាតុអាកាសអំណោយផលនោះក្រោយពីដាំបានចំនួន ៥-៦ ថ្ងៃ គ្រាប់ចាប់ផ្តើមដុះពន្លកទូលដីមកខាងលើ និងក្រោយពីដាំបានចំនួន ១៥-២០ ថ្ងៃ ការដុះលូតលាស់របស់ពូជនេះប្រព្រឹត្ត

ទៅយ៉ាងលឿន និងមានកម្ពស់ពី ៥០-៧០ សង់ទីម៉ែត្រ ដើមថ្លោស ស្លឹកឡើងពណ៌បៃតងស្រងាត់។ ពូជនេះចាប់ផ្ដើមចេញផ្កាឈ្មោល នៅពេលបានអាយុកាល ៥០-៥៣ ថ្ងៃ ក្រោយពីដាំ និងចេញផ្កាញីនៅពេលបានអាយុកាល ៥៣-៥៥ ថ្ងៃ ក្រោយពីដាំ និងចាប់ផ្ដើមទុំនៅរយៈពេល ៥៥-៦០ ថ្ងៃ ក្រោយពីចេញផ្កាញី។

## ការប្រើប្រាស់ជី

ការប្រើប្រាស់ជីតាមបច្ចេកទេស និងត្រឹមត្រូវតាមពេលវេលា ធ្វើឲ្យដំណាំដុះលូតលាស់ល្អ ទទួលបានទិន្នផលខ្ពស់។ ជីដែលអាចប្រើប្រាស់ គឺអាសូត ផូស្វ័រ និងប៉ូតាស្យូម (N : $P_2O_5$ : $K_2O$)។ កម្រិតនៃការប្រើប្រាស់ជី អាចប្រែប្រួលទៅតាមប្រភេទដី។ ការប្រើប្រាស់ជី ចែកចេញជាបីដំណាក់កាល គឺដាក់ទ្រាប់បាតមុនពេលដាំ ដោយប្រើប្រាស់ជីអាសូត (៥០ ភាគរយ) ផូស្វ័រ និងប៉ូតាស្យូម (១០០ ភាគរយ) ចំណែកអាសូតនៅសល់ (៥០ ភាគរយ) ប្រើសម្រាប់ដាក់បំប៉នចំនួនពីរលើកទៀត គឺលើកទី ១ (២៥ ភាគរយ) ក្រោយពីដាំបាន ២០-២៥ ថ្ងៃ និងបំប៉នលើកទី ២ (២៥ ភាគរយ) ក្រោយពីដាំបាន ៤០-៤៥ ថ្ងៃ។ ការដាក់ជី គឺយើងត្រូវដាក់ឲ្យឆ្ងាយពីគល់ពី ១០-១៥ ស.ម រួចពូនដីលប់ឲ្យជិត ដើម្បីទប់គល់ពោតផង និងការពារជីមិនឲ្យបាត់បង់តាមរយៈការហើរទៅក្នុងបរិយាកាស និងការហូរច្រោះដោយសារទឹក។

| ជី | កម្រិតជីទៅតាមប្រភេទដី (គ.ក/ហ.ត) | | | |
|---|---|---|---|---|
| | ដីខ្សាច់ (ព្រៃខ្មែរ ប្រទះឡាង) | ដីឥដ្ឋ (កំពង់សៀម ឡាបានសៀក) | ដីកណ្ដោង (ទួលសំរោង) | ដីល្បាប់ (កៀនស្វាយ) |
| អ៊ុយរ៉េ | ១២៤ | ១៧៤ | ១៧៤ | ១៥០ |
| ដេ អា ប៉េ | ៩៥ | ១០៧ | ១០៧ | ៨៥ |
| ប៉ូតាស្យូម | ៣៧ | ៤៥ | ៣៧ | ៥៤ |

## ការប្រមូលផល

គេអាចប្រមូលផលពោត នៅពេលដើមពោតចាប់ផ្ដើមប្រែពណ៌ពីសំបកក្ដាមទៅលឿងស្ងួត ឬងាប់ដើម សំបកផ្លែមានពណ៌លឿងស្ងួត ហើយស្រួយសក់ពោតឡើងស្ងួត ឬសម្គាល់មួយផ្នែកទៀតនៅលើគល់របស់គ្រាប់ឡើងពណ៌ប្រផេះ គឺនៅពេលពោតបានអាយុកាលពី ១០០-១១០ ថ្ងៃ បន្ទាប់ពីដាំ។ ការយឺតយ៉ាវក្នុងការប្រមូលផលនៅរដូវភ្លៀងធ្លាក់ជោគជាំ អាចធ្វើឲ្យផលនៃគ្រាប់ពោតធ្លាក់ចុះ និងបាត់បង់គុណភាព ដោយសារទឹកភ្លៀងជ្រាបចូលក្នុងផ្លែបណ្ដាលឲ្យគ្រាប់ដុះ ឬកើតជំងឺផ្សិតលើគ្រាប់។

## ការទុកដាក់ក្រោយពេលប្រមូលផល និងការរក្សាទុកគ្រាប់ពូជ



ជាមធ្យមសំណើមគ្រាប់ក្រោយពេលប្រមូលផលគឺពី ១៨-២០ ភាគរយ ដូច្នេះតម្រូវឲ្យយើងធ្វើការហាលសម្ងួតបន្ថែមទៀតដោយកម្ដៅថ្ងៃ។ ត្រូវឧស្សាហ៍ប្រែត្រឡប់គ្រាប់ខណៈកំពុងហាលដើម្បីឲ្យគ្រាប់ឆាប់ស្ងួតល្អ។ ការយឺតយ៉ាវក្នុងការហាលសម្ងួត និងទុកដាក់គ្រាប់ពោតមិនបានល្អក្រោយពេលប្រមូលផល អាចធ្វើឲ្យកកើតសត្វល្អិតចង្រៃ ដូចជាខ្ចូតជាដើមដែលវាស៊ីបំផ្លាញគ្រាប់ពោតតាំងពីនៅលើដើម រហូតដល់គ្រាប់នៅក្នុងកន្លែងរក្សាទុកគ្រាប់ពូជ។ មិនតែប៉ុណ្ណោះអាចធ្វើឲ្យបាត់បង់គុណភាព ដូចជាគ្រាប់កើតជំងឺផ្សិតធ្យូង គ្រាប់ឡើងផ្អួរដែលជាហេតុធ្វើឲ្យតម្លៃគ្រាប់ពោតធ្លាក់ចុះ។ ពូជពោត "លឿងមង្គល" ជាពូជដែលអាចរក្សាគ្រាប់ពូជទុកដាំដុះនៅរដូវបន្ទាប់ទៀតបាន មិនដូចពូជពោតអ៊ីប្រ៊ីដទេ ប្រសិនបើយើងដាំដុះ វានៅដាច់តែឯងគ្មានពូជពោតផ្សេងនៅក្បែរ។ ការរក្សាគ្រាប់ពូជទុកសម្រាប់ប្រើនៅរដូវបន្ទាប់ត្រូវមានសំណើមពី ១៣-១៥ ភាគរយ គឺទុកនៅកន្លែងស្ងួតល្អ ឬរក្សាទុកក្នុងធុងបិតជិត ឬអាចទុកដាក់ដោយប្រើប្រាស់ថ្នាំការពារសត្វល្អិត។

សម្រាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យរុក្ខជម្រើសវិទ្យា មជ្ឈមណ្ឌលបណ្ដុះបណ្ដាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្ដោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ ភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ

ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៩ ៦៩៣-៤ គេហទំព័រ: www.cardi.org.kh

ទូរអក្ខរ: pbreed@cardi.org.kh trin@cardi.org.kh hunyadana@cardi.org.kh